# កិច្ចលើកទង់តាមទំនៀមទម្លាប់ខ្មែរ

ក្នុងសង្គមខ្មែរ គេតែងសម្គាល់ឃើញអ្នកស្រុកធ្វើកិច្ចសំខាន់មួយពាក់ព័ន្ធនឹងការលើក "ទង់រលក" ឬហៅថា "ទង់ព្រះសូត្រ" (តំបន់ខ្លះធ្វើកិច្ចលើកទង់ក្រពើដែរ) ទាំងក្នុងបុណ្យលក្ខណៈបុគ្គលក្នុងគ្រួសារ ឬបុណ្យរួមក្នុងភូមិៗ ក្នុងកិច្ចនោះមានអាចារ្យជាប្រធានដឹកនាំធ្វើបន្ទាប់ពីកិច្ចប្រុងពលី[១] ឬចប់កិច្ចបួងសួងនាវេលាល្ងាចថ្ងៃសូត្រមន្តៗ បើនៅជុំវិញតំបន់អង្គរ អ្នកស្រុកតែងហៅកិច្ចលើកទង់ថា "ឆាកហ៊ោលើកទង់" ដ្បិតពេលនោះមានមនុស្សច្រើនកុះករ ស្រែកហ៊ោគ្រឹកគគ្រេង មុននឹងលើកទង់ឱ្យខ្ពស់ត្រដឹមត្រដែតឡើងៗ នៅក្នុងជំនឿ ពុទ្ធសាសនិកពន្យល់ថាការបូជាលើកទង់នេះមានអានិសង្សសម្រាប់ជាតិខាងមុខៗ ប៉ុន្តែក្នុងគំនិតអ្នកស្រាវជ្រាវយល់ថាឆាកហ៊ោលើកទង់ក៏មានន័យជា "ការបញ្ចៀស" ឬ "បណ្ដេញឧបទ្រពចង្រៃ" និងការចាប់កំណើតកើតឡើងវិញដែរៗ

ជាទូទៅទង់រលក ឬទង់ព្រះសូត្រ ច្រើនធ្វើពីកំណាត់ពណ៌ចម្រុះ ឬជួនកាលរំលេចដោយគ្រឿងចាំងនានាដែលគេយកមកដេរភ្ជាប់ៗ ចំពោះរូបសណ្ឋានទង់រលក ឬទង់ព្រះសូត្រក៏ពុំខុសពីទង់ក្រពើ ឬទង់អភិធម្មដែរៗ ទង់រលកមានរាងស្ទើរដូចដងខ្លួនមនុស្សមានឆ្អឹង ក្បាល ខ្លួន ដៃ និងជើង អ្នកស្រុកខ្លះថែមទាំងប៉ាក់ ឬដេរឱ្យមានភ្នែកទៀត ហើយអ្នកស្រាវជ្រាវមើលឃើញថា ទង់ជាវត្ថុដែលមានជីវិតៗ ដូច្នេះហើយបានជាអាចារ្យត្រូវបើកព្រះនេត្រសិន ក្រោយពេលដេរហើយ មុនយកទៅប្រើលើកដំបូងៗ នៅពេលមានបុណ្យធំៗ មុននឹងលើកត្រូវបំបួសទង់នោះសិន ហើយពេលចប់បុណ្យដាក់ចុះមកវិញ គេត្រូវផ្សឹកទង់នោះដែរៗ[២] ទង់នេះតែងធ្វើកិច្ចលើកក្នុងពិធីបុណ្យមានលក្ខណៈសប្បាយរីករាយដូចជាបុណ្យនានានៅតាមវត្ត ឬនៅផ្ទះអ្នកស្រុកៗ

ពាក់ព័ន្ធនឹងជំនឿលើទង់ បើផ្អែកតាមសាស្ត្រា "អានិសង្សទង់ពិតាន" បាននិយាយថា កាលក្នុងកទ្ទកប្បព្រះពុទ្ធកស្សបៈ មានបុរសទុគ៌តម្នាក់ប្រកបរបររកឧសនិងបេះ

---

[១] សូមអានបន្ថែម៖ "ប្រុងពលី" ដោយ ញឹម សុជាវិទ្ធ

ផ្សាយលើតំណ https://ams.com.kh/khmercivilization/detail/574 (២៩ សីហា ២០២៣)

[២] ម៉ៅ សេងយាន និងអាំង ជូលាន ២០០៧-២០០៨: ៣១-៣៥

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ផល្លានុផលក្នុងព្រៃ។ ថ្ងៃមួយបុរសកំសត់បានប្រទះឃើញព្រះស្តូបបុរាណកណ្តាលព្រៃ ក៏កើតចិត្តត្រេកអរថ្វាសទ្ធា ចូលទៅកាច់ផ្កាស្បូវក្ងាំង និងហែកសំពត់ធ្វើទង់បូជាព្រះស្តូបនោះ។ លុះអស់អាយុសង្ខារ បុរសនោះក៏បានទៅកើតនៅស្ថានភិមានប្រាសាទទេព មានលម្អដោយទង់ និងព្រឹក្សានានាជាទីសុខសាន្តមនោរម្យ។[៣] ប្រហែលដោយជាប់ជំនឿក្នុងនិទានខាងលើ ទើបនៅតាមព្រះវិហារមួយចំនួន គេតែងឃើញមានធ្វាក់ឧទ្ទិសដល់ព្រះចូឡាមណីយចេតិយ ដែលមានទង់រលកមួយគូនៅលើហោជាង (រូបលេខ១)។ មិនតែប៉ុណ្ណោះ ពុទ្ធសាសនិកក្នុងស្រុកភូមិខ្វះ ក៏តែងនាំគ្នាកាត់ដេរសាងទង់ ដង្ហែថ្វាយដល់វត្តជិតឆ្ងាយនានាទៅតាមជំនឿ និងទំនៀមជាហូរហែ។ នៅក្នុងទិដ្ឋភាពនេះ ភាគច្រើនគេកាត់ទង់ពីកំណាត់ពណ៌ចម្រុះ សាងឡើងឱ្យមានទំហំធំ និងរចនាលម្អដោយដេរភ្ជាប់កញ្ចក់ ឬប៉ាក់ឱនគ្រឿងចែងចាំងភ្លឺភ្លែកនានា និងចងកណ្តឹង ដង្ហែបូជាប្រទក្សិណជុំវិញព្រះវិហារ មុននឹងលើកចងបង្ហូតទៅចុងដងទង់ខាងមុខព្រះវិហារ (រូបលេខ២-៣)។

ដោយឡែក ចំពោះកិច្ចលើកទង់ ឬអ្នកស្រុករស់នៅតំបន់ភាគខាងជើងហៅរត់មាត់ថាឆាកហ៊ោលើកទង់ គឺតែងឃើញក្នុងពិធីបំបួសនាគ សម្ពោធភូមិ ឆ្លងចេត្រ ឆាន់សុំទឹកភ្លៀង បុណ្យអភិសេក ថ្វាយភ្លើងព្រះសព ឬពិធីបូជាសពរួមក្នុងភូមិជាដើម។[៤] ប៉ុន្តែថ្វីបើកិច្ចលើកទង់ ឬឆាកហ៊ោលើកទង់ធ្វើនៅខាងក្រោយកិច្ចប្រុងពលី ឬកិច្ចបួងសួង តែទង់នោះគេត្រូវរៀបចំឱ្យបានស្រេចទុកជាមួយរណ្តាប់បូជាប្រុងពលី និងបួងសួងដែរ (រូបលេខ២)។ បន្ទាប់មក ប្រសិនបើអ្នកស្រុកណាមានសេចក្តីជ្រះថ្លាប្រាថ្នាភ្ជាប់និស្ស័យនឹងទង់ គេតែងយកប្រាក់ទៅដាក់ចូលក្នុងថ្នក់ទង់ ឬដាក់ក្នុងថង់ភ្ជាប់នឹងទង់ មុននឹងធ្វើកិច្ចលើកទង់ (រូបលេខ៥)។ លុះអ្នកស្រុកចូលបូជាទង់ចប់ហើយ អាចារ្យក៏នាំសូត្រ "នមោ" បីចប់ និងសូត្រប្រកាសលើកទង់ទៅតាមទំនៀម។ ក្នុងពេលនោះ គេយកក្បាលទង់ចងភ្ជាប់នឹងចុងឫស្សី ហើយលាខ្លួនទង់ស្របនឹងដង ដោយមានអ្នកស្រុកច្រើនកុះករឈរត្រៀមត្រាកាន់ទ្រទង់ ហាក់ដូចជាពុំអាចឱ្យទង់នោះប៉ះដីបានឡើយ (រូបលេខ៦)។

---

[៣] សូមអានបន្ថែម៖ សាស្ត្រា "អានិសង្សទង់ ពិតាន" លេខបញ្ជីសារពើភណ្ឌ EFEO.C32 និងស៊ីយ៉ុន សុភារិទ្ធ ២០០៨

[៤] សូមអានបន្ថែម៖ គង់ វីរៈ ២០០៨-២០០៩: ១៣៥

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

## អត្ថបទ៖ កិច្ចលើកទង់តាមទំនៀមទម្លាប់ខ្មែរ

តាមធម្មតា ទិសដែលតែងឃើញលើកទង់ គឺនៅឦសាន ឬខាងកើតរោងបុណ្យ ដ្បិតជាទិសជំនឿនៃការចាប់កំណើតឡើងវិញ។ លើសពីនេះបើសង្កេតឱ្យល្អិតត្រង់គល់ដងទង់ អ្វីដែលគួរឱ្យពិចារណា គេច្រើនពុំដាំបញ្ចូលដងទង់ទៅក្នុងដីផ្ទាល់ទេ ពោលគឺគេដាប់គល់ដងទង់ ដោយប្រើរនុកភ្ជាប់ទៅបង្គោលពីរដើមសងខាង (រូបលេខ៧)។ ចំពោះការលើកទង់ ឬឆាកហោ៊លើកទង់ គេតែងឃើញមានមនុស្សម្នាក់ចាំស្រែកឆាកហោ៊៣ដង ហើយច្រើនតែជាមនុស្សមានសំឡេងពីរោះគ្រលួចផង។ ពេលខ្លះ គេថែមទាំងបន្ទឺសំឡេងឃោះពេលស្រែកឆាកហោ៊ចប់មួយវគ្គ ហាក់ដូចជាឱ្យកិច្ចនេះកាន់តែអឹងកងថែមទៀត។ បន្ទាប់ពីលើករួចរាល់ហើយ គេរក្សាទុកទង់នោះមួយយប់ (រូបលេខ៨-១០) រហូតដល់វេលាព្រឹកទើបគេធ្វើកិច្ចផ្សឹកទង់ដាក់ចុះមកវិញ។

សរុបមក លើកទង់ ឬឆាកហោ៊លើកទង់ គឺជាកិច្ចយ៉ាងសំខាន់របស់អ្នកស្រុកដែលមានអត្ថន័យពាក់ព័ន្ធនឹងព្រះពុទ្ធសាសនាផង និងមានខ្លឹមសារជាទំនៀមរបស់អ្នកស្រុកផង។ ប៉ុន្តែប្រការសំខាន់បំផុតដែលអ្នកស្រាវជ្រាវចាប់អារម្មណ៍ គឺកិច្ចលើកទង់តែងធ្វើក្រោយកិច្ចប្រុងពលីរួច ដែលហាក់បង្ហាញឱ្យឃើញអត្ថន័យពាក់ព័ន្ធនឹងគំនិ "ស្លាប់-កើត" ពោលគឺប្រុងពលី ជាការបូជា (កប់រូបនាងគង្ហីង និងរណ្តាប់) តែលើកទង់សំដៅកិច្ចដែលផ្ដោះទៅលើ ជាស្ថានខ្ពង់ខ្ពស់៕

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# បញ្ជីរូបភាព



រូបលេខ១ ចម្លាក់លើហោជាង៍វត្តល្អក់ (ខេត្តសៀមរាប) បង្ហាញពីការបូជាទង់ចំពោះព្រះស្តូប





រូបលេខ២-៣ អ្នកស្រុកដង្ហែទង់បូជាថ្វាយមុខព្រះវិហារ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




រូបលេខ២៤-៥ ទង់រលក ឬទង់ព្រះសូត្ររៀបចំក្នុងវណ្ដាប់បូជាក្នុងកិច្ចប្រុងពលី



រូបលេខ២៦ អ្នកស្រុកនាំគ្នាបូជាទង់ កាន់ទ្រធ្វើកិច្ចមុននឹងលើកនៅក្នុងបុណ្យឡើងមាឃ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



រូបលេខ៧ គល់បង្គោលដងទង់



រូបលេខ៨ ទង់រលកក្នុងបុណ្យសុំទឹកភ្លៀងនៅប្រាសាទនាគព័ន្ធ



រូបលេខ៩ ទង់រលកក្នុងបុណ្យឡើងមាឃនៅភូមិបង្កោង



រូបលេខ១០ ទង់រលកក្នុងបុណ្យបូជាសពរួមគ្នានៅភូមិដូនអុន (តំបន់អង្គរ)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

# ឯកសារពិគ្រោះ

គង់ វីរៈ

២០០៨-២០០៩, "ផាកហ៊ោ", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ២៤, ទំ.១៣៥-, Friend of Khmer Culture, ភ្នំពេញ

ញឹម សុធារិទ្ធ, "ប្រុងពលី" ផ្សាយលើគំណ https://ams.com.kh/khmercivilization/detail/574 (២៩ សីហា ២០២៣)

ស៊ីយ៉ុន សុភារិទ្ធ

២០០៨, *ពិធានទៅក្នុងជំនឿនិងកិច្ចប្រតិបត្ត*, រៃឃំ, ភ្នំពេញ

ម៉ៅ សេងយាន និង អាំង ជូលាន

២០០៧-២០០៨, "ទង់", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១៣, ទំ.៣១-៣៥, Friend of Khmer Culture, ភ្នំពេញ